**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ២៦៤៥ កសក

# សេចក្តីជូនដំណឹង
## ស្តីពី
## បញ្ឈប់ការនាំចូល ផ្គត់ផ្គង់ចែកចាយ និងប្រើប្រាស់ថ្នាំកសិកម្ម ដែលមានសារធាតុសកម្ម Tricyclazole

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន និងអ្នកផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជ្រាបថា យោងទៅលើសេចក្តីជូនដំណឹងរបស់សហភាពអឺរ៉ុប (EU) បានបម្រាមការនាំចូលអង្ករមានផ្ទុកសារជាតុ Tricyclazole ដែលបានកម្រិតលើសពី0,០១មីលីក្រាម ក្នុង១គីឡូក្រាម ទៅសហភាពអឺរ៉ុប។ យោងលើហេតុផលនេះ ដើម្បីរក្សាគុណភាព និងធានាសុខុមាលភាពសាធារណៈ ក៏ដូចជាការរក្សានូវកេរ្តិ៍ឈ្មោះនៃគុណភាពអង្កររបស់ព្រះរាជាណាចក្រកម្ពុជា និងឆ្លើយតបទៅនឹងតម្រូវការទីផ្សារអន្តរជាតិនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដូចតទៅ៖

១-រាល់អ្នកប្រើប្រាស់ថ្នាំកសិកម្មទាំងអស់ ត្រូវបញ្ឈប់ការប្រើប្រាស់ថ្នាំកសិកម្ម ដែលមានសារធាតុសកម្ម Tricyclazole ទៅលើដំណាំស្រូវ ដែលអាចបន្សល់ទុកនូវសំណល់ថ្នាំកសិកម្មនៅក្នុងអង្ករ។

២-គ្រប់ក្រុមហ៊ុនដែលធ្វើពាណិជ្ជកម្មថ្នាំកសិកម្មទាំងអស់ ត្រូវបញ្ឈប់ការនាំចូលថ្នាំកសិកម្មដែលមានសារធាតុសកម្ម Tricyclazole ។

៣-រាល់អ្នកផ្គត់ផ្គង់ចែកចាយទាំងអស់ ត្រូវបញ្ឈប់ការផ្គត់ផ្គង់ចែកចាយដល់សាខា ឬដេប៉ូ លក់ដុំ លក់រាយ ថ្នាំកសិកម្ម ដែលមានសារធាតុសកម្ម Tricyclazole ។

៤-មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចុះត្រួតពិនិត្យ និងណែនាំ អប់រំ ផ្សព្វផ្សាយដល់ដេប៉ូ លក់ដុំ លក់រាយ និងអ្នកប្រើប្រាស់ថ្នាំកសិកម្មឱ្យបានយល់ដឹង ដើម្បីទប់ស្កាត់នូវការប្រើប្រាស់ថ្នាំកសិកម្ម ដែលមានសារធាតុសកម្ម Tricyclazole និងត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់ប្រជាកសិករ។

៥-នាយកដ្ឋាននីតិកម្មកសិកម្ម ត្រូវបញ្ឈប់ការចុះបញ្ជិកា និងការអនុញ្ញាតឱ្យនាំចូលថ្នាំកសិកម្ម ដែលមានសារធាតុសកម្ម Tricyclazole ។

៦-អគ្គនាយកដ្ឋានកសិកម្ម ត្រូវសិក្សាស្រាវជ្រាវបន្ថែម ដើម្បីរកប្រភេទថ្នាំកសិកម្មថ្មីដែលគ្មានសារធាតុហាមឃាត់មកជំនួសវិញ និងត្រូវបន្តពង្រឹងការត្រួតពិនិត្យផ្នែកអនាម័យនិងភូតគាមអនាម័យ ពិសេសសំណល់ថ្នាំកសិកម្មឱ្យបានសមស្របតាមវិធានបច្ចេកទេស បម៉ាណីយ និងនីតិវិធីជាធរមាន មុនអនុញ្ញាតឱ្យនាំចេញអង្ករ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធក្នុងករណីចាំបាច់។

ទទួលបានសេចក្តីជូនដំណឹងនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមហ៊ុនធ្វើពាណិជ្ជកម្មថ្នាំកសិកម្ម និងអ្នកប្រើប្រាស់ទាំងអស់ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិនា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ឯកសារ កាលប្បវត្តិ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (០២៣)៧២៦ ១២៨ /៧២៦ ១២៩ ទូរសារលេខ: (៨៥៥)២៣-២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320